**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

*ថ្ងៃចន្ទ ១២ រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧*
*រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែសីហា ឆ្នាំ ២០២៣*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ជំនួបរវាងឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយលោកជំទាវ ខាមែន ម៉ូរេនូ (Carmen Moreno) ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំកម្ពុជា

នាព្រឹកថ្ងៃទី ២៨ ខែសីហា ឆ្នាំ ២០២៣, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានអនុញ្ញាតលោកជំទាវ **ខាមែន ម៉ូរេនូ** (Carmen Moreno) ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំកម្ពុជា ចូលជួបសម្តែងការគួរសម និងជម្រាបលា ស្របពេលដែលលោកជំទាវត្រូវបញ្ចប់អាណត្តិបេសកកម្មការទូតនៅកម្ពុជា ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់លោកជំទាវ **ខាមែន ម៉ូរេនូ** ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការ រវាងកម្ពុជា និងសហភាពអឺរ៉ុប ក្នុងអំឡុងពេលដែលលោកជំទាវបានបំពេញបេសកកម្មការទូតរបស់ខ្លួន និងបានសម្តែងនូវអំណរគុណចំពោះសហភាពអឺរ៉ុប ដែលតែងតែផ្តល់ការគាំទ្រដល់កិច្ចអភិវឌ្ឍក្នុងវិស័យអាទិភាពនានារបស់រាជរដ្ឋាភិបាល និងលើការដ្ឋានការងារកែទម្រង់សំខាន់ៗ ដែលសម្រេចបានសមិទ្ធផលជាច្រើនគួរជាទីមោទនៈ ទោះស្ថិតក្នុងគ្រាលំបាកនៃផលប៉ះពាល់ពីវិបត្តិនៃជំងឺកូវីដ-១៩ និងសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះក្តី ។

លោកជំទាវ **ខាមែន ម៉ូរេនូ** បានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលធានាបាននូវស្ថិរភាពនយោបាយ និងសង្គម-សេដ្ឋកិច្ច និងការអភិវឌ្ឍប្រទេសលើគ្រប់វិស័យ ។ ឆ្លៀតក្នុងឱកាសនេះ, លោកជំទាវឯកអគ្គរដ្ឋទូត ក៏បានចូលរួមអបអរសាទរជាមួយប្រជាជនកម្ពុជា ដែលទើបទទួលបាននូវរាជរដ្ឋាភិបាលថ្មី កើតចេញពីការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ។ លោកជំទាវក៏បានសម្តែងនូវការពេញចិត្តយ៉ាងខ្លាំង ចំពោះការដាក់ចេញនូវកម្មវិធីនយោបាយមុតស្រួចច្បាស់លាស់ ពោលគឺ **យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី ១** របស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រ

**កម្ពុជា** ។ លោកជំទាវបានសង្កត់ធ្ងន់ថា សហភាពអឺរ៉ុបនឹងបន្តផ្តល់កិច្ចសហប្រតិបត្តិការល្អ និងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបន្តគាំទ្រដល់របៀបវារៈ និងកម្មវិធីកែទម្រង់ជាអាទិភាពនានារបស់រាជរដ្ឋាភិបាល សំដៅបន្តចូលរួមចំណែកក្នុងការលើកស្ទួយកម្រិតជីវភាពរស់នៅរបស់ប្រជាជនគ្រប់ស្រទាប់វណ្ណៈ ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសហភាពអឺរ៉ុបដែលមានឆន្ទៈ និងការប្តេជ្ញាចិត្តខ្ពស់ ក្នុងការបន្តចូលរួមចំណែកក្នុងកិច្ចអភិវឌ្ឍនៅកម្ពុជា ដោយបានគូសបញ្ជាក់ថា សហភាពអឺរ៉ុបគឺជាដៃគូពាណិជ្ជកម្មដ៏ធំ និងសំខាន់របស់កម្ពុជា និងជឿជាក់ថា ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការនេះ នឹងកាន់តែរឹងមាំ និងកាន់តែស៊ីជម្រៅបន្ថែមទៀត បន្ទាប់ពីឯកអគ្គរដ្ឋទូតថ្មីរបស់សហភាពអឺរ៉ុបប្រចាំកម្ពុជា ចូលកាន់តំណែងនាពេលដ៏ខ្លីខាងមុខ ។ ជាទីបញ្ចប់, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានជូនពរលោកជំទាវ **ខាមែន ម៉ូរេនូ** ទទួលបានជោគជ័យថ្មីៗបន្ថែមទៀត ក្នុងការបំពេញភារកិច្ច និងតួនាទីថ្មីរបស់លោកជំទាវ នាអនាគត ។